00402289

ឯកសារ/ន: D242

នៅចំពោះសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Declassified to Public
12 April 2013

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | ភាសាអង់គ្លេស |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 11 / 2009
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 11 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា** (DC-Cam)

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** |
|---|---|
| សហព្រះរាជអាជ្ញា: | សហចៅក្រមស៊ើបអង្កេត: |
| លោកស្រី ជា លាង | ចៅក្រម យូ ប៊ុនឡេង |
| លោក William SMITH | ចៅក្រម Marcel LEMONDE |
| លោក យ៉េត ចរិយា | |

**ជនត្រូវចោទ និង ក្រុមមេធាវី:**

**នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**អៀង សារី**

លោក អាង ឧត្តម

លោកMichaelG.KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS

**ខៀវ សំផន**

លោក សរ ស្វូវាន

លោក Jacques VERGES

**កាំង ហ្កេកអ៊ាវ *ហៅ*ឌុច**

លោក ការ សាវុត្ថ

លោក François ROUX

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESSANDRATANA

លោកស្រី Annie DELAHAIE

លោកស្រី Fabienne TRUSSES-NAPROUS

លោក នី ចាន់ឌី

លោក ឡេ ជុនធី

កញ្ញា SILKE Studzinsky

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

លោក Pierre-Olivier SUR

លោកស្រី ស៊ីន សុវ៉ន

លោក Mahdev MOHAN

លោកស្រី NGUYEN Lyma

កញ្ញា Marie GUIRAUD

លោក Patrick BAUDOUIN

លោក Olivier BAHOUGNE

លោក David BLACKMAN

## សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៥៥.១០ នៃវិធានផ្ទៃក្នុង ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើឱ្យសហចៅក្រមស៊ើបអង្កេត ("សចស" ឬ "កសចស") បំពេញកិច្ចស៊ើបសួរ ("សំណើ") មានដូចតទៅ ។

២. សហព្រះរាជអាជ្ញា បានពិនិត្យឡើងវិញលើភស្តុតាងដែលបានដាក់ក្នុងសំណុំរឿងរហូតដល់ថ្ងៃនេះ ក្នុងគោលបំណងសម្រាប់ធ្វើការកំណត់សម្រេចទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលជាការចាំបាច់ដើម្បីកំណត់អំពីការពិត និងដើម្បីមានកំណត់ត្រាអង្គហេតុពេញលេញទាំងស្រុងមួយ ទាក់ទិននឹងបញ្ហាជាកម្មវត្ថុនៃកិច្ចស៊ើបសួរនេះ ។ ដោយផ្អែកលើការពិនិត្យឡើងវិញនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យ កសចៅ បំពេញកិច្ចស៊ើបសួរ ដូចជំរាបជូនខាងក្រោម ។

## ប្រវត្តិអង្គហេតុ

៣. មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) គឺជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យមួយដែលធ្វើការប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីរបបខ្មែរក្រហម ដោយផ្អែកទៅលើការស្រាវជ្រាវដែលមិនលំអៀងនៅលើអង្គហេតុ និងប្រវត្តិសាស្ត្រ ។ បេសកកម្មរបស់ DC-Cam គឺដើម្បីកត់ត្រាទុកជាកំណត់ហេតុ និងថែរក្សាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម សម្រាប់មនុស្សជំនាន់ក្រោយ ព្រមទាំងដើម្បីប្រមូលចងក្រង និងរៀបចំព័ត៌មានដែលអាចបំរើជាភស្តុតាង នៅក្នុងដំណើរការតុលាការចំពោះបទឧក្រិដ្ឋនានារបស់ខ្មែរក្រហម ។

៤. DC-Cam បានធ្វើការស្រាវជ្រាវ និងធ្វើសកម្មភាពផ្សេងៗយ៉ាងទូលំទូលាយ លើការងារចងក្រងឯកសារ តាំងពីឆ្នាំ១៩៩៥ មក ។ បណ្ណសាររបស់មជ្ឈមណ្ឌលនេះ មានផ្ទុកនូវឯកសារចំនួនជាង ៥៥៥,០០០ ទំព័រ និងប្រភេទនៃសំភារៈឯកសារមួយចំនួនធំទៀត ។ DC-Cam គឺជាឃ្លាំងរក្សាទុកឯកសារចំបងរបស់កម្ពុជាប្រជាធិបតេយ្យដែលធំជាងគេបង្អស់នៅក្នុងលោក ។ ហេតុដូច្នេះហើយ

បានជាមានការរំពឹងទុកដោយសមហេតុផលថា DC-Cam នឹងត្រូវបានកោះអញ្ជើញដើម្បីឱ្យធ្វើជាប្រភពដើមដ៏សំខាន់បំផុតនៃសំភារៈជាភស្តុតាងសម្រាប់ អវតក[1] ។

៥. នៅក្នុងដំណើរការនៃកិច្ចស៊ើបសួរបឋម កសព បានពឹងផ្អែកយ៉ាងខ្លាំងទៅលើបណ្ណសាររបស់ DC-Cam សម្រាប់ជាប្រភពនៃព័ត៌មាន និងភស្តុតាង ។ ក្រុមអ្នកវិភាគមួយរបស់ កសព ត្រូវបានបញ្ជូនទៅកាន់ DC-Cam និងបានពិនិត្យទៅលើបណ្ណសាររបស់មជ្ឈមណ្ឌលនេះ ក្នុងអម្លុងនៃដំណើរការដែលមានរយៈពេលប៉ុន្មានខែ ដោយបានធ្វើការប្រមែប្រមូលចំណែកនៃភស្តុតាងជាច្រើនដែលបានដាក់បង្ហាញជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ជាង១,៥០០ សូមមើល ឧបសម្ព័ន្ធ១) ឬនៅក្នុងដំណាក់កាលក្រោយៗមកទៀត (ជាង៤០០, សូមមើល ឧបសម្ព័ន្ធ២) ។ រហូតមកដល់ថ្ងៃនេះ កសព បានដាក់បង្ហាញឯកសារដើមពី DC-Cam ចំនួនជាង១,៩០០ ឯកសារ ទៅក្នុងសំណុំរឿង ។ ប៉ុន្តែការពិនិត្យឡើងវិញរបស់ កសព ទៅលើបណ្ណសាររបស់ DC-Cam គឺនៅមានកំរិត ទាក់ទងនឹងពេលវេលា និងវិសាលភាព អាស្រ័យដោយសារឧបសគ្គនានាដែលមានជាប់មកជាមួយនឹងចរិតនៃកិច្ចស៊ើបសួរបឋម ។ លើសពីនេះ គេជឿថា ដោយសារនិរន្តភាពនៃសកម្មភាពរបស់ DC-Cam បណ្ណសាររបស់ DC-Cam ពេលនេះ ក៏ត្រូវតែប្រែមុខមាត់ទៅតាមសំភារៈឯកសារថ្មីៗ ដែលមិនទាន់មានក្នុងពេលនៃកិច្ចស៊ើបសួរបឋម ។

៦. តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានស្នើរួចហើយដល់អ្នកស៊ើបអង្កេត កសចស *"ឱ្យពិគ្រោះយោបល់ និង/ឬ ថតចម្លងឯកសារណាមួយ, បណ្ណសារជាសម្លេង/រូបភាព ឬឯកសារដទៃទៀត ដែលកំពុងស្ថិតក្នុងការកាន់កាប់របស់ [DC-Cam] ទាក់ទិននឹង [...] កិច្ចស៊ើបសួរដែលកំពុងបន្ត [...] ដើម្បីពិចារណាទៅលើភស្តុតាងដាក់ និងដោះបន្ទុក [ដែលប្រមូលបាន] សម្រាប់ដាក់ទៅក្នុងសំណុំរឿងឱ្យបានទាន់ពេលវេលា"*[2] ។ ប៉ុន្តែ ទោះបីជាអាណត្តិការងារដ៏ធំទូលាយនេះ ត្រូវបានប្រគល់ជូនដល់អ្នកស៊ើបអង្កេតក៏ដោយ ក៏ការអនុវត្តន៍នូវដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ ជាលទ្ធផលគេទទួលបានតែឯកសារចំនួន

[1] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤ បានថ្លែងថា: "គេរំពឹងទុកថា អង្គជំនុំជម្រះនឹងពឹងផ្អែកយ៉ាងខ្លាំងទៅលើភស្តុតាងជាឯកសារ ។ ភស្តុតាងជាឯកសារចំនួន ២០០,០០០ ទំព័រ ត្រូវបានគេរំពឹងទុកថា នឹងមានការពិនិត្យ ។ ឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនេះ កំពុងស្ថិតនៅក្រោមការកាន់កាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលឧទ្ទិសការងាររបស់ខ្លួនចំពោះការស្រាវជ្រាវ និងថែរក្សាឯកសារអំពីបទឧក្រិដ្ឋនានាដែលបានកើតឡើងក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ" ។ សូមអាន: A/59/432, កថាខ័ណ្ឌទី១៩ ។

[2] *សូមអាន:* ឯកសារ D175 ។

២២៩ តែប៉ុណ្ណោះដែលត្រូវបានដាក់នៅលើសំណុំរឿង[3]។ បន្ថែមពីលើនេះ កសព បានដាក់ឯកសារ DC-Cam មួយចំនួនទៅក្នុងសំណុំរឿង ប៉ុន្តែជាក់ស្តែង ឯកសារទាំងអស់នោះ គឺជាឯកសារសំណុំរឿងលេខ០០១ ដែលត្រូវបានបង្វែរទៅក្នុងសំណុំរឿង០០២ វិញ ឬជាឯកសារផ្សេងដែលទាក់ទងនឹងមន្ទីរស-២១[4] ។

## មូលដ្ឋានច្បាប់

៧. មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក បានអនុញ្ញាតឱ្យ សហចៅក្រមស៊ើបអង្កេត "អាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មាន ដែលទទួលបានពីស្ថាប័ននានា រួមមាន *[...] អង្គការក្រៅរដ្ឋាភិបាលជាដើម*" ។

៨. វិធាន ៥៥.៥ នៃវិធានផ្ទៃក្នុង បានចែងបន្ថែមទៀតថា "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់ ។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេត ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ ។ ដើម្បីបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាច៖ [...] គ. *ស្វែងរកព័ត៌មាន និងជំនួយពី [...] ឬ [...] ឬអង្គការក្រៅរដ្ឋាភិបាល* ឬប្រភពសមស្របដទៃទៀត" ។

៩. វិធាន ៥៥.១០ នៃវិធានផ្ទៃក្នុងបានចែងថា "នៅគ្រប់ពេលវេលានៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា [...] *អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត [...] បំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ*" ។

## សេចក្តីសំអាង

១០. សហព្រះរាជអាជ្ញា យល់ឃើញថា ការកំណត់អត្តសញ្ញាណនៃភស្តុតាងពាក់ព័ន្ធ ដែលមាននៅក្នុងបណ្ណសាររបស់ DC-Cam និងការដាក់ភស្តុតាងទាំងនោះបញ្ចូលទៅក្នុងសំណុំរឿង គឺជាការ

[3] សូមអាន: ឧបសម្ព័ន្ធ ៣, សំណោរនៅខាងក្រោម D175 ។

[4] *សូមអាន:* ឧបសម្ព័ន្ធ ៣, សំណោរនៅខាងក្រោម D108 និង D121 ។

បំពេញកិច្ចស៊ើបសួរមួយដ៏ចាំបាច់ ដែលមានសារៈសំខាន់ដ៏លើសលុបដែលជាជោគជ័យនៅក្នុងការបំពេញការស៊ើបសួរនេះ ។

១១. ដោយមានមូលដ្ឋាននៅលើឯកសាររបស់ DC-Cam មួយចំនួនតូច ដែលរហូតមកទល់ពេលនេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង និងដោយមានមូលដ្ឋាននៅលើទំហំ និងមាតិកានៃបណ្ណសាររបស់ DC-Cam សហព្រះរាជអាជ្ញាជឿជាក់ថា វាទំនងជាមានភស្តុតាងដែលមានការពាក់ព័ន្ធ និងជាភវនីយហេតុ ដើម្បីបង្ហាញសក្ខីកម្មគាំទ្រ ឬក៏សក្ខីកម្មជំទាស់ទៅនឹងការចោទប្រកាន់នានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ក.ស.ព មានការព្រួយបារម្ភថាការខកខានមិនបានចម្រាញ់យកប្រយោជន៍ចេញពីបណ្ណសារ និងចំណេះដឹងអំពីស្ថាប័នខ្មែរក្រហម របស់ DC-Cam ឱ្យបានពេញសក្តានុពលទាំងស្រុង ថាជាប្រភពនៃភស្តុតាងមួយទេនោះៗ វាអាចនឹងមានការប៉ះពាល់ទៅលើការខំប្រឹងខ្នះខ្នែងរបស់ ស.ច.ស ក្នុងការស្វែងរកការពិត ទៅលើកម្មវត្ថុនៃកិច្ចស៊ើបសួរនេះ ។

១២. ដើម្បីចម្រាញ់យកប្រយោជន៍ឱ្យបានពេញសក្តានុពលទាំងស្រុង ចេញពីបណ្ណសាររបស់ DC-Cam ដែលជាប្រភពនៃភស្តុតាងមួយនោះ សហព្រះរាជអាជ្ញា ជឿជាក់ថា ការពិនិត្យឡើងវិញទាំងស្រុង និងជាប្រព័ន្ធពីសំណាក់ DC-Cam គឺជាការចាំបាច់មួយសំដៅរកការកំណត់អត្តសញ្ញាណលើភស្តុតាងពាក់ព័ន្ធនឹងបញ្ហានីមួយៗ ដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរនេះ ។ ដោយយល់ឃើញថា ទំហំនៃបណ្ណសារ ពេលវេលាដែលមានកំរិត និងលទ្ធផលដែលបានមកតាមការស្នើសុំនានាពីលើកមុននៅមានកំរិត សហព្រះរាជអាជ្ញា សូមស្នើថា វិធីដ៏មានប្រសិទ្ធិភាពបំផុតក្នុងការអនុវត្តន៍នូវការពិនិត្យឡើងវិញបែបដូច្នេះ គឺត្រូវស្នើសុំឱ្យ DC-Cam អនុវត្តដោយខ្លួនឯង ដោយមានមូលដ្ឋាននៅលើបញ្ជីវាយមុខបញ្ហានានាមួយដែល ក.ស.ច.ស បានប្រគល់ឱ្យ ។

១៣. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យ សហចៅក្រមស៊ើបអង្កេត ស្វែងរកការស្នើសុំឱ្យ DC-Cam ជួយដល់ពួកខ្លួនតាមរយៈការពិនិត្យឡើងវិញនូវបណ្ណសាររបស់ខ្លួន ដើម្បីកំណត់អត្តសញ្ញាណនៃភស្តុតាងទាក់ទងនឹងកម្មវត្ថុនៃកិច្ចស៊ើបសួរនេះ ទៅតាមបញ្ជីដែលមានភ្ជាប់មកជាមួយនឹងសំណើជា **"ឧបសម្ព័ន្ធ ៤"** និងបញ្ជូនភស្តុតាងទាំងនោះមក ស.ច.ស ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង ។

## សេចក្តីសន្និដ្ឋាន

១៤. សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត បំពេញការស៊ើបសួរទាំងឡាយដូចខាងក្រោមនេះ៖

ក. ស្នើសុំឱ្យ DC-Cam ជួយដល់សហចៅក្រមស៊ើបអង្កេត ដោយធ្វើការពិនិត្យឡើងវិញនូវបណ្ណសាររបស់ពួកគេ ដើម្បីកំណត់អត្តសញ្ញាណនៃភស្តុតាងទាក់ទងនឹងកម្មវត្ថុនៃកិច្ចស៊ើបសួរនេះ ទៅតាមបញ្ជីដែលមានភ្ជាប់មកជាមួយ “**ឧបសម្ព័ន្ធ ៤**” និងបញ្ជូនភស្តុតាងទាំងនោះមកសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ | **លោក យ៉េត ចរិយា**<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | [signature and stamp] |
| | **លោក** William SMITH<br>**សហព្រះរាជអាជ្ញា (ស្តីទី)** | | |